**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៨២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ស្ថិតិផ្លូវការដែលបានចាត់តាំង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៨ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ៣០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះបម្រើសំណូមពរព័ត៌មានស្ថិតិរបស់អ្នកធ្វើគោលនយោបាយក្នុងការរៀបចំវាយតម្លៃគោលនយោបាយនិងកម្មវិធីសេដ្ឋកិច្ច សង្គមកិច្ច ដើម្បីឆ្លើយតបនឹងកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រទេស ក៏ដូចជាបម្រើសេចក្តីត្រូវការព័ត៌មានរបស់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិនិងអន្តរជាតិដ៏ទូលំទូលាយ ដោយកំណត់ឱ្យក្រសួង ស្ថាប័នរាជរដ្ឋាភិបាលប្រមូលចងក្រងនិងគ្រប់គ្រង ស្ថិតិផ្លូវការដែលបានចាត់តាំងទៅតាមវិស័យរបស់ខ្លួន។

**មាត្រា២.-**

អនុក្រឹត្យនេះមានវិសាលភាពគ្រប់គ្រងរាល់ស្ថិតិផ្លូវការដែលបានចាត់តាំងនិងអង្គភាពស្ថិតិដែលបានចាត់តាំងនៅតាមក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដូចមានចែងក្នុងច្បាប់ស្តីពីស្ថិតិ។

**មាត្រា៣.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចខាងក្រោម៖

**អង្គភាពស្ថិតិដែលបានចាត់តាំង** សំដៅដល់អង្គភាពស្ថិតិកណ្តាលនៅតាមក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដែលត្រូវបានកំណត់ដោយរាជរដ្ឋាភិបាលឱ្យទទួលខុសត្រូវក្នុងការផលិតស្ថិតិផ្លូវការដែលបានចាត់តាំង។

## ជំពូកទី២
## ស្ថិតិផ្លូវការដែលបានចាត់តាំងរបស់វិទ្យាស្ថានជាតិស្ថិតិ

**មាត្រា៤.-**

អនុលោមតាមស្មារតីនៃច្បាប់ស្តីពីស្ថិតិ គ្រប់ទិន្នន័យស្ថិតិទាំងអស់ដែលបានប្រកាសផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ គឺជាស្ថិតិផ្លូវការដែលបានចាត់តាំង។ វិទ្យាស្ថានជាតិស្ថិតិត្រូវប្រកាសផ្សាយដល់សាធារណជននូវស្ថិតិគ្រឹះនិងស្ថិតិតាមវិស័យ ទោះផលិតដោយខ្លួនឯងឬដោយសហការជាមួយអង្គភាពស្ថិតិផ្សេងទៀតរបស់រាជរដ្ឋាភិបាល៖

១- ស្ថិតិជំរឿន

- ជំរឿនប្រជាជនរៀងរាល់១០(ដប់)ឆ្នាំម្តង
- ជំរឿនកសិកម្មរៀងរាល់១០(ដប់)ឆ្នាំម្តង
- ជំរឿនសេដ្ឋកិច្ចរៀងរាល់១០(ដប់)ឆ្នាំម្តង។

២- ស្ថិតិអង្កេត

- អង្កេតចន្លោះជំរឿនប្រជាជនរៀងរាល់៥(ប្រាំ)ឆ្នាំម្តងបន្ទាប់ពីជំរឿន
- អង្កេតចន្លោះជំរឿនកសិកម្មរៀងរាល់៥(ប្រាំ)ឆ្នាំម្តងបន្ទាប់ពីជំរឿន
- អង្កេតចន្លោះជំរឿនសេដ្ឋកិច្ចរៀងរាល់៥(ប្រាំ)ឆ្នាំម្តងបន្ទាប់ពីជំរឿន
- អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជារៀងរាល់៥(ប្រាំ)ឆ្នាំម្តង
- អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាប្រចាំឆ្នាំ
- អង្កេតកម្លាំងពលកម្មកម្ពុជាប្រចាំឆ្នាំ
- អង្កេតមនុស្សចាស់កម្ពុជារៀងរាល់៥(ប្រាំ)ឆ្នាំម្តង
- អង្កេតអំពើហិង្សាលើស្ត្រីរៀងរាល់៥(ប្រាំ)ឆ្នាំម្តង
- អង្កេតអំពើហិង្សាលើកុមាររៀងរាល់៥(ប្រាំ)ឆ្នាំម្តង
- អង្កេតកុមារបម្រើតាមផ្ទះរៀងរាល់៥(ប្រាំ)ឆ្នាំម្តង
- អង្កេតសហគ្រាសឧស្សាហកម្មកម្ពុជាប្រចាំឆ្នាំ
- អង្កេតហិរញ្ញវត្ថុវិស័យកសិកម្មប្រចាំឆ្នាំ
- អង្កេតកសិកម្មកម្ពុជាប្រចាំឆ្នាំ

- អង្កេតស្ថិតិថ្នាក់ក្រោមជាតិរៀងរាល់២(ពីរ)ឆ្នាំម្តង
- អង្កេតពិការភាពកម្ពុជារៀងរាល់៥(ប្រាំ)ឆ្នាំម្តង
- អង្កេតការអប់រំនិងអក្ខរភាពរៀងរាល់៥(ប្រាំ)ឆ្នាំម្តង
- អង្កេតសេដ្ឋកិច្ចផ្នែកមិនរៀបរយរៀងរាល់៥(ប្រាំ)ឆ្នាំម្តង។

៣- ស្ថិតិសេដ្ឋកិច្ច

- ស្ថិតិចុះបញ្ជីសហគ្រាសអាជីវកម្មប្រចាំឆ្នាំ
- ស្ថិតិទំនិញពាណិជ្ជកម្មអន្តរជាតិនៃកម្ពុជាប្រចាំឆ្នាំ
- ស្ថិតិចំណូលនិងចំណាយគ្រួសារប្រចាំឆ្នាំ
- ស្ថិតិសន្ទស្សន៍ថ្លៃអ្នកផលិតនិងសេវាកម្ម
- ស្ថិតិគណនេយ្យជាតិថ្នាក់ជាតិនិងថ្នាក់រាជធានី ខេត្តប្រចាំត្រីមាសនិងប្រចាំឆ្នាំ
- ស្ថិតិសន្ទស្សន៍ថ្លៃផលិតកម្មកសិកម្មនិងឧស្សាហកម្មប្រចាំត្រីមាសនិងប្រចាំឆ្នាំ
- ស្ថិតិសន្ទស្សន៍ថ្លៃលក់រាយនិងលក់ដុំប្រចាំត្រីមាសនិងប្រចាំឆ្នាំ
- ស្ថិតិសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ស្ថិតិសន្ទស្សន៍ថ្លៃនីហរណ៍និងអាហរណ៍ប្រចាំខែនិងប្រចាំត្រីមាស
- ស្ថិតិគណនីរណបទេសចរណ៍ដោយសហការជាមួយក្រសួងទេសចរណ៍រៀងរាល់២(ពីរ)ឆ្នាំម្តង
- ស្ថិតិគណនីរណបអប់រំដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡារៀងរាល់៥(ប្រាំ)ឆ្នាំម្តង
- ស្ថិតិគណនីរណបសុខាភិបាលដោយសហការជាមួយក្រសួងសុខាភិបាលរៀងរាល់៥(ប្រាំ)ឆ្នាំម្តង
- ស្ថិតិគណនីរណបសេដ្ឋកិច្ចនិងបរិស្ថានដោយសហការជាមួយក្រសួងបរិស្ថានរៀងរាល់៥(ប្រាំ)ឆ្នាំម្តង
- ស្ថិតិសន្ទស្សន៍ថ្លៃពលកម្មនិងថ្លៃឈ្នួលរៀងរាល់២(ពីរ)ឆ្នាំម្តង។

៤- ស្ថិតិបរិស្ថាននិងធនធានធម្មជាតិ

- ស្ថិតិបរិស្ថាននិងធនធានធម្មជាតិរៀងរាល់៥(ប្រាំ)ឆ្នាំម្តង
- ស្ថិតិគណនីរណបជលផលដោយសហការជាមួយរដ្ឋបាលជលផលរៀងរាល់៥(ប្រាំ)ឆ្នាំម្តង។

៥- ស្ថិតិសង្គមកិច្ច

- ស្ថិតិអប់រំ យុវជន និងកីឡាប្រចាំឆ្នាំ
- ស្ថិតិការងារនិងពលកម្មប្រចាំឆ្នាំ
- ស្ថិតិសុខាភិបាលប្រចាំឆ្នាំ
- ស្ថិតិពិការភាពប្រចាំឆ្នាំ
- ស្ថិតិវប្បធម៌ ព័ត៌មាន និងសាសនាប្រចាំឆ្នាំ
- ស្ថិតិសង្គមកិច្ចដទៃទៀត។

៦- កម្រងស្ថិតិ

- សៀវភៅកម្រងទិន្នន័យស្ថិតិប្រចាំឆ្នាំ
- សៀវភៅស្ថិតិថ្នាក់ក្រោមជាតិប្រចាំឆ្នាំ។

៧- ប្រព័ន្ធទិន្នន័យស្ថិតិក្រុមសង្កេតការណ៍ភពផែនដី

- ស្ថិតិដែលទទួលបានរូបភាពពីផ្កាយរណបឬទិន្នន័យចាប់យកពីចម្ងាយ និងការប្រមូលទិន្នន័យផ្ទាល់ទាក់ទងនឹងគ្រោះមហន្តរាយ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ សម្រាប់ចូលរួមអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

៨- ប្រព័ន្ធទិន្នន័យសូចនាករអភិវឌ្ឍន៍

- សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា អាស៊ាន និងសាកល
- សូចនាករតាមដានវឌ្ឍនភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- សូចនាករតាមដានវឌ្ឍនភាពផែនការយុទ្ធសាស្ត្រតាមវិស័យផ្សេងៗទៀត។

អំឡុងពេលដែលមានចែងក្នុងចំណុចទី១ដល់ចំណុចទី៨នេះ អាចធ្វើការផ្លាស់ប្តូរបានក្នុងករណីចាំបាច់។

វិទ្យាស្ថានជាតិស្ថិតិត្រូវរៀបចំធ្វើអង្កេតនិងប្រមូលចងក្រងស្ថិតិផ្លូវការដទៃទៀត តាមការចាំបាច់សម្រាប់តម្រូវការប្រើប្រាស់។

## ជំពូកទី៣
## ស្ថិតិផ្លូវការដែលបានចាត់តាំងរបស់អង្គភាពស្ថិតិផ្សេងទៀត

**មាត្រា៥ .-**

អង្គភាពស្ថិតិដែលបានចាត់តាំងនៅតាមក្រសួង ស្ថាប័នរាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវក្នុងការប្រមូលចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិដល់សាធារណជននូវស្ថិតិផ្លូវការដែលបានចាត់តាំងដូចតទៅ៖

១- ក្រសួងមហាផ្ទៃ

- ស្ថិតិប្រជាពលរដ្ឋប្រចាំឆ្នាំ
- ស្ថិតិអត្តសញ្ញាណប័ណ្ណប្រចាំឆ្នាំ
- ស្ថិតិការចុះបញ្ជីអត្រានុកូលដ្ឋានប្រចាំឆ្នាំ
- ស្ថិតិបទល្មើសព្រហ្មទណ្ឌនិងការបង្ក្រាបប្រចាំឆ្នាំ
- ស្ថិតិជនជាប់ឃុំនិងការអប់រំកែប្រែប្រចាំឆ្នាំ
- ស្ថិតិជនអន្តោប្រវេសន៍ប្រចាំឆ្នាំ
- ស្ថិតិគណបក្សនយោបាយប្រចាំឆ្នាំ
- ស្ថិតិសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកប្រចាំឆ្នាំ
- ស្ថិតិការបង្កើតរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ។

២- ទីស្តីការគណៈរដ្ឋមន្ត្រី

- ស្ថិតិវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

៣- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលប្រចាំខែនិងប្រចាំឆ្នាំ
- ស្ថិតិបំណុលសាធារណៈប្រចាំត្រីមាសនិងប្រចាំឆ្នាំ

- ស្ថិតិការអនុវត្តថវិការដ្ឋប្រចាំខែនិងប្រចាំឆ្នាំ
- ស្ថិតិចំណូលសារពើពន្ធប្រចាំឆ្នាំ
- ស្ថិតិចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំ
- ស្ថិតិពាណិជ្ជកម្មទំនិញអន្តរជាតិប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ។

**៤- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច**

- ស្ថិតិការចុះផ្សព្វផ្សាយច្បាប់ប្រចាំឆ្នាំ
- ស្ថិតិការអនុម័តច្បាប់ប្រចាំឆ្នាំ
- ស្ថិតិសមាជិករដ្ឋសភា ព្រឹទ្ធសភាប្រចាំឆ្នាំ
- ស្ថិតិការចុះធ្វើអធិការកិច្ចនៅតាមក្រសួង ស្ថាប័នប្រចាំឆ្នាំ
- ស្ថិតិទទួលនិងដោះស្រាយពាក្យបណ្ដឹងប្រចាំឆ្នាំ។

**៥- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**

- ស្ថិតិស្ថានតំណាងកម្ពុជាប្រចាំនៅបរទេស
- ស្ថិតិស្ថានតំណាងបរទេសប្រចាំកម្ពុជា
- ស្ថិតិទីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំកម្ពុជា
- ស្ថិតិអង្គការអន្តរជាតិនិងអង្គការមិនមែនរដ្ឋាភិបាលបរទេស
- ស្ថិតិប្រទេសលើកលែងទិដ្ឋាការជាមួយកម្ពុជា។

**៦- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- ស្ថិតិវិស័យសំណង់ប្រចាំឆ្នាំ
- ស្ថិតិវិស័យដីធ្លីប្រចាំឆ្នាំ
- ស្ថិតិវិស័យរៀបចំដែនដី នគរូបនីយកម្មប្រចាំឆ្នាំ។

**៧- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

- ស្ថិតិឧស្សាហកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- ស្ថិតិសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- ស្ថិតិទឹកស្អាតប្រចាំឆ្នាំ
- ស្ថិតិក្នុងការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្មប្រចាំឆ្នាំ។

**៨- ក្រសួងសាធារណការនិងដឹកជញ្ជូន**

- ស្ថិតិការចុះបញ្ជីយានយន្តនិងនាវាប្រចាំឆ្នាំ
- ស្ថិតិសាធារណការនិងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនប្រចាំឆ្នាំ
- ស្ថិតិគ្រោះថ្នាក់ចរាចរណ៍តាមផ្លូវថ្នល់ ផ្លូវដែក និងផ្លូវទឹកប្រចាំឆ្នាំ។

៩- ធនាគារជាតិនៃកម្ពុជា

**ក- ស្ថិតិវិស័យក្រៅប្រទេស**

- ស្ថិតិជញ្ជីងទូទាត់ប្រចាំត្រីមាស
- ស្ថិតិបំណុលក្រៅប្រទេសប្រចាំត្រីមាស
- ស្ថិតិស្ថានភាពវិនិយោគអន្តរជាតិប្រចាំត្រីមាស។

**ខ- ស្ថិតិរូបិយវត្ថុនិងហិរញ្ញវត្ថុ**

- ស្ថិតិស្ថានភាពធនាគារកណ្តាលប្រចាំខែ
- ស្ថិតិស្ថានភាពគ្រឹះស្ថានទទួលប្រាក់បញ្ញើផ្សេងទៀតប្រចាំខែ
- ស្ថិតិស្ថានភាពគ្រឹះស្ថានទទួលប្រាក់បញ្ញើប្រចាំខែ
- ស្ថិតិស្ថានភាពគ្រឹះស្ថានហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើប្រចាំខែ
- ស្ថិតិស្ថានភាពគ្រឹះស្ថានហិរញ្ញវត្ថុប្រចាំខែ។

**គ- ស្ថិតិគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**

- ស្ថិតិទ្រព្យសកម្មបែងចែកតាមប្រភេទគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រចាំត្រីមាស
- ស្ថិតិទ្រព្យអកម្មបែងចែកតាមប្រភេទគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រចាំត្រីមាស
- ស្ថិតិអត្រាការប្រាក់ឥណទាននិងប្រាក់បញ្ញើប្រចាំត្រីមាស
- ស្ថិតិចំនួនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រចាំត្រីមាស
- ស្ថិតិចំនួនសាខារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រចាំត្រីមាស
- ស្ថិតិចំនួនម៉ាស៊ីនដកនិងដាក់ប្រាក់ប្រចាំត្រីមាស។

**ឃ- ស្ថិតិប្រព័ន្ធទូទាត់**

- ស្ថិតិចំនួនប្រតិបត្តិការទូទាត់អន្តរជាតិប្រចាំខែ
- ស្ថិតិចំនួនគ្រឹះស្ថានទូទាត់សងប្រាក់ប្រចាំត្រីមាស។

**១០- ក្រសួងអប់រំ យុវជន និងកីឡា**

- ស្ថិតិមត្តេយ្យសិក្សានិងបឋមសិក្សាប្រចាំឆ្នាំ
- ស្ថិតិមធ្យមសិក្សាបឋមភូមិនិងមធ្យមសិក្សាទុតិយភូមិប្រចាំឆ្នាំ
- ស្ថិតិឧត្តមសិក្សាប្រចាំឆ្នាំ
- ស្ថិតិអប់រំក្រៅប្រព័ន្ធប្រចាំឆ្នាំ។

**១១- ក្រសួងពាណិជ្ជកម្ម**

- ស្ថិតិការចុះបញ្ជីពាណិជ្ជកម្មប្រចាំឆ្នាំ
- ស្ថិតិការចុះបញ្ជីម៉ាកប្រចាំឆ្នាំ
- ស្ថិតិចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញប្រចាំឆ្នាំ
- ស្ថិតិក្រុមហ៊ុន រោងចក្រ ចុះបញ្ជីនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មប្រចាំឆ្នាំ
- ស្ថិតិនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មប្រចាំឆ្នាំ។

១២- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- ស្ថិតិសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ស្ថិតិបេឡាជាតិ អតីតយុទ្ធជនប្រចាំឆ្នាំ
- ស្ថិតិបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលប្រចាំឆ្នាំ។

១៣- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ស្ថិតិថ្លៃទំនិញកសិកម្មប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ស្ថិតិផ្ទៃដីដាំដុះតាមប្រភេទដំណាំ ទិន្នផល និងបរិមាណផលដំណាំប្រចាំរដូវនិងប្រចាំឆ្នាំ
- ស្ថិតិផលិតកម្មនិងបសុព្យាបាលប្រចាំឆ្នាំ
- ស្ថិតិជលផលប្រចាំឆ្នាំ
- ស្ថិតិព្រៃឈើប្រចាំឆ្នាំ
- ស្ថិតិផលិតកម្មដំណាំកៅស៊ូប្រចាំឆ្នាំ
- ស្ថិតិគ្រឿងយន្តកសិកម្មប្រចាំឆ្នាំ
- ស្ថិតិថ្នាំកសិកម្មនិងសម្ភារៈកសិកម្មប្រចាំឆ្នាំ
- ស្ថិតិនាំចេញកសិផល។

១៤- ក្រសួងអភិវឌ្ឍន៍ជនបទ

- ស្ថិតិផ្លូវជនបទប្រចាំឆ្នាំ
- ស្ថិតិទឹកស្អាតជនបទប្រចាំឆ្នាំ
- ស្ថិតិបង្គន់អនាម័យជនបទប្រចាំឆ្នាំ
- ស្ថិតិក្រុមជនជាតិភាគតិចប្រចាំឆ្នាំ
- ស្ថិតិផ្នែកប្រព័ន្ធធារាសាស្ត្រខ្នាតតូចប្រចាំឆ្នាំ
- ស្ថិតិឥណទានអភិវឌ្ឍន៍ជនបទប្រចាំឆ្នាំ។

១៥- ក្រសួងរ៉ែនិងថាមពល

- ស្ថិតិផលិតកម្មថាមពលអគ្គិសនីប្រចាំឆ្នាំ
- ស្ថិតិនាំចូលថាមពលអគ្គិសនីប្រចាំឆ្នាំ
- ស្ថិតិអានុភាពថាមពលអគ្គិសនីប្រចាំឆ្នាំ
- ស្ថិតិអាជ្ញាបណ្ណធនធានរ៉ែប្រចាំឆ្នាំ។

១៦- ក្រសួងធនធានទឹកនិងឧតុនិយម

- ស្ថិតិឧតុនិយមប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំ
- ស្ថិតិជលសាស្ត្រប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំ
- ស្ថិតិលទ្ធភាពស្រោចស្រពផ្ទៃដីដំណាំស្រូវប្រចាំឆ្នាំ។

១៧- ក្រសួងបរិស្ថាន

- ស្ថិតិការវាយតម្លៃលើការប្រែប្រួលធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិប្រចាំឆ្នាំ
- ស្ថិតិការវាយតម្លៃលើការប្រែប្រួលអាកាសធាតុរៀងរាល់៤(បួន)ឆ្នាំម្តង
- ស្ថិតិការវាយតម្លៃលើការបំពុលសំណល់រឹង សំណល់រាវ និងគុណភាពទឹកសាធារណៈប្រចាំឆ្នាំ
- ស្ថិតិការវាយតម្លៃលើការបំពុលសំណល់គ្រោះថ្នាក់និងការបំពុលខ្យល់រៀងរាល់៣(បី)ឆ្នាំ
- ស្ថិតិគម្រោងដែលត្រូវបានធ្វើការវាយតម្លៃបាយការណ៍ផលប៉ះពាល់បរិស្ថាននិងសង្គមប្រចាំឆ្នាំ។

១៨- ក្រសួងយុត្តិធម៌

- ស្ថិតិសំណុំរឿងគ្រប់ប្រភេទនៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ប្រចាំឆ្នាំ
- ស្ថិតិសេចក្តីព្រាងច្បាប់ សេចក្តីព្រាងអនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តដែលបានផ្តួចផ្តើមដោយក្រសួងយុត្តិធម៌ប្រចាំឆ្នាំ
- ស្ថិតិកិច្ចការផ្សព្វផ្សាយច្បាប់ប្រចាំឆ្នាំ
- ស្ថិតិសាលក្រម សាលដីការបស់តុលាការគ្រប់ជាន់ថ្នាក់ប្រចាំឆ្នាំ
- ស្ថិតិនៃសេចក្តីព្រាងច្បាប់ សេចក្តីព្រាងអនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តដែលត្រូវបានពិនិត្យនិងផ្តល់យោបល់ដោយក្រសួងយុត្តិធម៌
- ស្ថិតិកិច្ចការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យយុត្តិធម៌ប្រចាំឆ្នាំ
- ស្ថិតិការទទួលពាក្យសុំនិងចេញព្រឹត្តិបត្រថ្កោលទោសប្រចាំឆ្នាំ
- ស្ថិតិកិច្ចការអធិការកិច្ចនៅតាមតុលាការគ្រប់ជាន់ថ្នាក់ប្រចាំឆ្នាំ។

១៩- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- ស្ថិតិអាជីវកម្មសេវាកម្មប្រៃសណីយ៍ប្រចាំឆ្នាំ
- ស្ថិតិអាជីវកម្មសេវាកម្មទូរគមនាគមន៍ប្រចាំឆ្នាំ
- ស្ថិតិវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានប្រចាំឆ្នាំ
- ស្ថិតិបណ្តុះបណ្តាលធនធានមនុស្សលើវិស័យប្រៃសណីយ៍ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានប្រចាំឆ្នាំ។

២០- ក្រសួងសុខាភិបាល

- ស្ថិតិជំងឺឆ្លងប្រចាំខែនិងប្រចាំឆ្នាំ
- ស្ថិតិសុខាភិបាលប្រចាំឆ្នាំ
- ស្ថិតិមូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជនមានច្បាប់ប្រចាំឆ្នាំ។

២១- ក្រសួងព័ត៌មាន

- ស្ថិតិផ្នែកបណ្តាញផ្សព្វផ្សាយវិទ្យុ ទូរទស្សន៍ និងសារព័ត៌មានប្រចាំឆ្នាំ។

២២- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- ស្ថិតិការចុះបញ្ជីកម្មសិទ្ធិបញ្ញានិងសិទ្ធិអ្នកនិពន្ធប្រចាំឆ្នាំ
- ស្ថិតិភ្ញៀវចូលទស្សនាទីតាំងវប្បធម៌សំខាន់ៗប្រចាំឆ្នាំ

- ស្ថិតិទាក់ទងនឹងវិស័យភាពយន្តប្រចាំឆ្នាំ
- ស្ថិតិអង្គការ សមាគម ក្រុមហ៊ុន និងស្ថាប័នដែលធ្វើការលើវិស័យវប្បធម៌ប្រចាំឆ្នាំ
- ស្ថិតិត្រួតពិនិត្យវត្ថុសិល្បៈថ្មីនិងវត្ថុសិល្បៈចម្លងដូចសម្រាប់នាំចេញប្រចាំឆ្នាំ
- ស្ថិតិបេតិកភណ្ឌវប្បធម៌រូបីនិងអរូបីដទៃទៀតប្រចាំឆ្នាំ។

២៣- ក្រសួងទេសចរណ៍

- ស្ថិតិទេសចរណ៍អន្តរជាតិប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ
- ស្ថិតិទេសចរណ៍ជាតិប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ
- ស្ថិតិទេសចរណ៍ជាតិចេញក្រៅប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ
- មូលដ្ឋានអាជីវកម្មទេសចរណ៍ប្រចាំត្រីមាសនិងប្រចាំឆ្នាំ
- សេវាកម្មស្នាក់នៅប្រចាំត្រីមាសនិងប្រចាំឆ្នាំ
- មុខរបរនិងការងារទេសចរណ៍ប្រចាំឆ្នាំ
- ចំណូលទេសចរណ៍អន្តរជាតិប្រចាំឆ្នាំ។

២៤- ក្រសួងធម្មការនិងសាសនា

- ស្ថិតិព្រះសង្ឃសាសនាប្រចាំឆ្នាំ
- ស្ថិតិពាហិរសាសនាប្រចាំឆ្នាំ
- ស្ថិតិវិស័យពុទ្ធិកសិក្សាជាតិទាំងបីកម្រិតនិងធម្មវិន័យប្រចាំឆ្នាំ។

២៥- ក្រសួងកិច្ចការនារី

- ស្ថិតិយេនឌ័រប្រចាំឆ្នាំ។

២៦- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

- ស្ថិតិការងារផ្លូវការថ្មីដែលបានចុះបញ្ជីប្រចាំឆ្នាំ
- ស្ថិតិការអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈប្រចាំឆ្នាំ
- ស្ថិតិបេឡាជាតិសន្តិសុខសង្គមប្រចាំឆ្នាំ
- ស្ថិតិបេឡាជាតិសន្តិសុខសង្គមសម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈប្រចាំឆ្នាំ។

២៧- ក្រសួងមុខងារសាធារណៈ

- ស្ថិតិមន្ត្រីរាជការស៊ីវិលនិងសេវាសាធារណៈប្រចាំឆ្នាំ។

២៨- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

- ស្ថិតិក្រុមហ៊ុនអាកាសចរណ៍ប្រចាំឆ្នាំ
- ស្ថិតិអាកាសយានដ្ឋានប្រចាំឆ្នាំ
- ស្ថិតិដឹកជញ្ជូនផ្លូវអាកាស(អ្នកដំណើរ ជើងហោះហើរ និងទំនិញ)ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ
- ស្ថិតិអាកាសយានស៊ីវិលដែលចុះបញ្ជីប្រចាំឆ្នាំ។

២៩- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- សរុបការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍប្រចាំឆ្នាំ
- សរុបការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍ សម្រាប់ការគាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មប្រចាំឆ្នាំ
- ស្ថិតិការអនុម័តគម្រោងវិនិយោគឯកជនរួមទាំងគម្រោងវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេសប្រចាំឆ្នាំ។

៣០- ទីភ្នាក់ងារជាតិមុខរបរនិងការងារនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល

- របាយការណ៍ព័ត៌មានទីផ្សារការងារប្រចាំឆ្នាំ
- ស្ថិតិអ្នកស្វែងរកការងារធ្វើនិងតម្រូវការជ្រើសរើសកម្លាំងពលកម្មប្រចាំឆ្នាំ
- ស្ថិតិអង្កេតតម្រូវការជ្រើសរើសកម្លាំងពលកម្មរៀងរាល់២(ពីរ)ឆ្នាំម្តង
- ស្ថិតិអង្កេតការខ្វះជំនាញនិងកម្លាំងពលកម្មរៀងរាល់២(ពីរ)ឆ្នាំម្តង
- ស្ថិតិអង្កេតស្តីពីប្រាក់ឈ្នួលរៀងរាល់២(ពីរ)ឆ្នាំម្តង
- ស្ថិតិការផ្គត់ផ្គង់និងតម្រូវការជំនាញនិងកម្លាំងពលកម្មបច្ចុប្បន្ននិងការព្យាករប្រចាំឆ្នាំ។

អង្គភាពស្ថិតិដែលបានចាត់តាំងនៅតាមក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ត្រូវទទួលខុសត្រូវក្នុងការប្រមូល ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយព័ត៌មានដល់សាធារណជនអំពីស្ថិតិផ្លូវការដទៃទៀត តាមការចាំបាច់សម្រាប់តម្រូវការទិន្នន័យប្រើប្រាស់។

អំឡុងពេលដែលមានចែងក្នុងចំណុចទី១ដល់ចំណុចទី៣០នេះ អាចធ្វើការផ្លាស់ប្តូរបានក្នុងករណីចាំបាច់។

## ជំពូកទី៤
## ការគ្រប់គ្រងទិន្នន័យនិងប្រភពប្រមូលទិន្នន័យ

**មាត្រា៦ .-**

រាល់ការធ្វើជំរឿននិងអង្កេតត្រូវដឹកនាំធ្វើដោយវិទ្យាស្ថានជាតិស្ថិតិ។ ចំពោះការអង្កេតតាមវិស័យត្រូវដឹកនាំដោយអង្គភាពស្ថិតិដែលបានចាត់តាំងដោយខ្លួនឯងឬដោយសហប្រតិបត្តិការជាមួយវិទ្យាស្ថានជាតិស្ថិតិ។ វិទ្យាស្ថានជាតិស្ថិតិនិងអង្គភាពស្ថិតិដែលបានចាត់តាំងត្រូវប្រកាសផ្សាយទិន្នន័យជំរឿននិងអង្កេតតាមកម្រិតលម្អិតបំផុតដែលអាចធ្វើទៅបាន ហើយធានាការសម្ងាត់ទិន្នន័យដែលបានកត់ត្រាពីបុគ្គលម្នាក់ៗនិងគុណភាពទិន្នន័យស្ថិតិ។

អង្គភាពស្ថិតិដែលបានចាត់តាំងត្រូវប្រមូលនិងចងក្រងស្ថិតិដូចមានចែងខាងក្រោមនេះអំពី៖

- ទិន្នន័យរដ្ឋបាលឬការអង្កេតតាមវិស័យដែលប្រមូលដោយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សមាគម និងសង្គមស៊ីវិល
- ទិន្នន័យថ្នាក់ក្រោមជាតិ
- ទិន្នន័យប្រកាសផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ។

**មាត្រា៧ .-**

រាល់ទិន្នន័យរដ្ឋបាល ជំរឿន និងអង្កេតដែលមានស្រាប់ ដែលត្រូវបានដឹកនាំធ្វើដោយវិទ្យាស្ថានជាតិស្ថិតិ និងក្រសួង ស្ថាប័នរាជរដ្ឋាភិបាលផ្សេងទៀត ត្រូវផ្តល់ឈ្មោះស្ថិតិនៅវិទ្យាស្ថានជាតិស្ថិតិ ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។

រាល់ការប្រមូលទិន្នន័យរដ្ឋបាល ជំរឿន និងអង្កេតថ្មីដែលបានគ្រោងទុក ត្រូវផ្តល់ឈ្មោះស្ថិតិនៅវិទ្យាស្ថានជាតិស្ថិតិ មុននឹងចាប់ផ្តើមអនុវត្តការងារ។

ក្រសួងផែនការត្រូវផ្សព្វផ្សាយដល់អង្គភាពស្ថិតិផ្លូវការដែលបានចាត់តាំងនូវទម្រង់បែបបទសម្រាប់បំពេញនិងកាលបរិច្ឆេទដែលត្រូវអនុវត្ត។

**មាត្រា៨ .-**

ដោយផ្អែកលើយន្តការសម្របសម្រួលពីរ ដូចមានចែងក្នុងមាត្រា១៦និងមាត្រា១៧នៃច្បាប់ស្តីពីស្ថិតិ គឺក្រុមប្រឹក្សាស្ថិតិនិងគណៈកម្មាធិការសម្របសម្រួលស្ថិតិ រដ្ឋមន្ត្រីក្រសួងផែនការត្រូវអនុម័តនិងធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិស្តីពីការប្រមូលទិន្នន័យរដ្ឋបាល ការធ្វើជំរឿន និងអង្កេត ឬការផ្តល់ទិសដៅរួមបញ្ចូលគ្នា ការកែប្រែឬការបញ្ឈប់នូវការប្រមូលទិន្នន័យរដ្ឋបាល ការធ្វើជំរឿន និងអង្កេត ដើម្បីបំបាត់នូវភាពជាន់គ្នានិងបង្កើនជាអតិបរមានូវការប្រើប្រាស់សមត្ថភាពសម្ភាសន៍តាមមូលដ្ឋាន និងការកែច្នៃទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ។

**មាត្រា៩ .-**

អង្គភាពស្ថិតិដែលបានចាត់តាំងនៅតាមក្រសួង ស្ថាប័នរាជរដ្ឋាភិបាលត្រូវបញ្ជូននូវរាល់ព័ត៌មាននិងទិន្នន័យស្ថិតិដែលផលិតបានជាទម្រង់អេឡិចត្រូនិកនិងឯកសារជាក្រដាស ទៅវិទ្យាស្ថានជាតិស្ថិតិឱ្យបានទៀងទាត់និងទាន់ពេលវេលា។

**មាត្រា១០ .-**

រដ្ឋមន្ត្រីក្រសួងផែនការត្រូវបញ្ជូនបញ្ជីនៃរាល់ការប្រមូលទិន្នន័យរដ្ឋបាល ជំរឿន និងអង្កេតដែលមានស្រាប់ ការចំណាយ និងស្ថានភាពនៃការប្រមូលទិន្នន័យនីមួយៗទៅទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងរយៈពេល ១២(ដប់ពីរ)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។ ជារៀងរាល់ឆ្នាំ រដ្ឋមន្ត្រីក្រសួងផែនការត្រូវបញ្ជូនបញ្ជីប្រមូលទិន្នន័យរដ្ឋបាល ជំរឿន និងអង្កេតថ្មីៗទៅទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា១១ .-**

វិទ្យាស្ថានជាតិស្ថិតិត្រូវបង្កើតនិងថែរក្សាទុកនូវបញ្ជីឈ្មោះប្រភពទិន្នន័យរដ្ឋបាលនិងស្ថិតិដោយផ្អែកលើការប្រមូលព័ត៌មានម៉េតាទិន្នន័យតាមរយៈដំណើរការចុះបញ្ជី។ បញ្ជីឈ្មោះម៉េតាទិន្នន័យត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំនិងប្រកាសផ្សាយតាមគេហទំព័រ/វេបសាយរបស់វិទ្យាស្ថានជាតិស្ថិតិ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

អនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង និងបទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ច រៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៣កើត ខែ ភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

កិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ